## ចុះបើម៉ាស៊ីនភ្លើងចល័តគឺជាផ្នែកមួយនៃផែនការបម្រុងទុករបស់ខ្ញុំ?

ម៉ាស៊ីនភ្លើងចល័តអាចប្រើប្រាស់ ដើម្បីផ្តល់ថាមពលអគ្គិសនីក្នុងអំឡុងពេលដាច់ភ្លើង។ នៅពេលដោតបរិក្ខារពេទ្យរបស់អ្នកដោយផ្ទាល់ទៅក្នុងម៉ាស៊ីនភ្លើងចល័តបណ្តោះអាសន្ន ត្រូវអនុវត្តតាមសេចក្តីណែនាំរបស់ក្រុមហ៊ុនផលិតដោយប្រុងប្រយ័ត្ន។ មិនត្រូវព្យាយាមភ្ជាប់ម៉ាស៊ីនភ្លើងទៅខ្សែភ្លើងក្នុងផ្ទះដាច់ខាត។ មានតែជាងភ្លើងដែលមានអាជ្ញាប័ណ្ណប៉ុណ្ណោះគួរធ្វើកិច្ចការនេះ។ ម៉ាស៊ីនភ្លើងចល័តមិនត្រូវភ្ជាប់ដោយផ្ទាល់ជាមួយនឹងខ្សែថាមពលរបស់សេវាកម្មសាធារណៈឡើយ។

## តើខ្ញុំត្រូវអោយ SCE ដឹងឬទេ ប្រសិនបើខ្ញុំទិញម៉ាស៊ីនភ្លើង?

បាទ/ចាស ច្បាប់រដ្ឋតម្រូវថា អ្នកឲ្យសេវាកម្មសាធារណៈរបស់អ្នកដឹងថាតើ ម៉ាស៊ីនភ្លើងកំពុងត្រូវបានប្រើប្រាស់នៅផ្ទះ ឬអាជីវកម្មរបស់អ្នកដែរឬអត់។ ដើម្បីជូនដំណឹងដល់យើងខ្ញុំ សូមទូរស័ព្ទមកលេខ **1-800-655-4555**។

## សម្រាប់ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានបន្ថែម ឬប្រសិនបើអ្នកត្រូវការជំនួយក្នុងការបំពេញពាក្យរបស់អ្នក សូមទូរស័ព្ទមកយើងខ្ញុំតាមរយៈលេខ **1-800-447-6620** ឬចូលមើលគេហទំព័រ **sce.com/medicalbaseline**។



Energy for What's Ahead®

**Multicultural services**

Cambodian / ខ្មែរ 1-800-843-1309
Chinese / 中文 1-800-843-8343
Korean / 한국어 1-800-628-3061
Vietnamese / Tiếng Việt 1-800-327-3031
Spanish / Español 1-800-441-2233

©2018 Southern California Edison. All rights reserved.
SCE 14-539-6-CA REV 7/18 CAMBODIAN

SOUTHERN CALIFORNIA EDISON®
Energy for What's Ahead®

# ប្រាក់ឧបត្ថម្ភគោលទំហៀបសម្រាប់ផ្នែកវេជ្ជសាស្ត្រ

នៅពេលដែលអ្នកត្រូវការបរិក្ខារពេទ្យដែលដើរដោយថាមពលអគ្គិសនីនៅក្នុងផ្ទះរបស់អ្នក។



# ប្រាក់ឧបត្ថម្ភគោលទំហៀប សម្រាប់ផ្នែកវេជ្ជសាស្ត្រ

ប្រសិនបើអ្នក ឬនរណាម្នាក់នៅក្នុងគ្រួសាររបស់អ្នកត្រូវការប្រើជាប្រចាំនូវបរិក្ខារពេទ្យដែលដើរដោយថាមពលអគ្គិសនី ឬឧបករណ៍ពេទ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផ្សេងទៀត កម្មវិធីប្រាក់ឧបត្ថម្ភគោលទំហៀបសម្រាប់ផ្នែកវេជ្ជសាស្ត្ររបស់យើងអាចផ្តល់ អគ្គិសនី 16.5 គីឡូវ៉ាត់ម៉ោងបន្ថែមក្នុងមួយថ្ងៃ។* ត្រូវបានផ្តល់ជូននៅអត្រាគោលទំហៀបទាបបំផុត នេះជួយទូទាត់ផាត់សងការចំណាយនៃដំណើរការរបស់បរិក្ខារពេទ្យ។

មិនថាប្រាក់ចំណូលរបស់គ្រួសារអ្នកប៉ុន្មានទេ អ្នកអាចនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ប្រសិនបើអ្នកបំពេញបានតាមលក្ខខណ្ឌតម្រូវទាមទារនៃភាពមានសិទ្ធិសក្តិសមទទួលដូចខាងក្រោម។ យើងសូមលើកទឹកចិត្តអោយឱ្យអ្នកដាក់ពាក្យសុំប្រាក់ឧបត្ថម្ភគោលទំហៀបសម្រាប់ផ្នែកវេជ្ជសាស្ត្រ។

## តើខ្ញុំដឹងដោយរបៀបណា ថាតើខ្ញុំមានសិទ្ធិសក្តិសមទទួលបាន ឬអត់នោះ?

អ្នកអាចមានសិទ្ធិសក្តិសមទទួលបានប្រាក់ឧបត្ថម្ភគោលទំហៀបសម្រាប់ផ្នែកវេជ្ជសាស្ត្រ ប្រសិនបើអ្នក ឬអ្នករស់នៅពេញម៉ោងម្នាក់ផ្សេងទៀតនៅក្នុងផ្ទះរបស់អ្នក៖

1. ត្រូវការប្រើជាប្រចាំនូវបរិក្ខារពេទ្យ /បរិក្ខារទ្រទ្រង់ជីវិតដែលដើរដោយថាមពលអគ្គិសនី ដើម្បីទ្រទ្រង់ ប្តូរជំនួស ឬស្តារឡើងវិញនូវមុខងារផ្លូវកាយដ៏សំខាន់ និង/ ឬ
2. ត្រូវបានទទួលរងប៉ះពាល់ដោយសភាពជំងឺរួមមានជំងឺស្រោមកោសិកាប្រសាទឡើងរឹងក្រិនច្រើនកន្លែង រោគស្បែកឡើងក្រិន ឬខ្វិនជើងទាំងពីរខ្វិនអវយវៈទាំងបួន ឬស្លាប់ពាក់កណ្តាលខ្លួន (សូមមើលបញ្ជីនៅលើគេហទំព័រ **sce.com/medicalbaseline**) **ឬ**
3. មានជំងឺដែលគំរាមកំហែងដល់អាយុជីវិត ឬប្រព័ន្ធភាពស៊ាំចុះខ្សោយដែលត្រូវការប្រព័ន្ធម៉ាស៊ីនកម្តៅ និង / ឬម៉ាស៊ីនត្រជាក់។

អតិថិជនដែលទទួលបានប្រាក់ឧបត្ថម្ភគោលទំហៀបសម្រាប់ផ្នែកវេជ្ជសាស្ត្រជាពិសេសសម្រាប់ការប្រើប្រាស់ម៉ាស៊ីនត្រជាក់ទាក់ទងនឹងសភាពជំងឺ មិនមានសិទ្ធិសក្តិសមចូលរួមក្នុងគម្រោងបញ្ចុះតម្លៃរដូវក្តៅរបស់ SCE’ ទេ។

## តើអ្វីទៅជាបរិក្ខារពេទ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់?

ឧបករណ៍ដែលផ្គត់ផ្គង់ដោយថាមពលអគ្គិសនីដែលទ្រទ្រង់ជីវិតតាមបែបមេកានិច ឬបែបសិប្បនិម្មិត ឬស្តារឡើងវិញ ឬជំនួសមុខងារផ្លូវកាយសំខាន់ៗរួមមានចលភាព ត្រូវបានចាត់ទុកថាជាបរិក្ខារពេទ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ នេះរួមបញ្ចូលប៉ុន្តែមិនកំណត់ត្រឹមតែបរិក្ខារទ្រទ្រង់ជីវិតប៉ុណ្ណោះទេ។ ឧបករណ៍ដែលគេប្រើសម្រាប់ព្យាបាល ប៉ុន្តែមិនចាំបាច់ផ្នែកវេជ្ជសាស្ត្រសម្រាប់ទ្រទ្រង់ជីវិតគឺមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ។

* ចំពោះអតិថិជនប្រើប្រាស់ថាមពលឧស្ម័ននៅលើកោះ Santa Catalina ការលៃទុកជាគោលទំហៀបសម្រាប់ផ្នែកវេជ្ជសាស្ត្រជាបទដ្ឋានគឺ 0.822 ឯកតាកម្តៅ (therms) ក្នុងមួយថ្ងៃ។

## តើខ្ញុំដាក់ពាក្យស្នើសុំដូចម្តេច?

បំពេញផ្នែក អតិថិជន (ផ្នែកទី 1) នៃពាក្យស្នើសុំដែលភ្ជាប់មកជាមួយ។ បន្ទាប់មកអោយអ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់អ្នកជំងឺបំពេញ និងចុះហត្ថលេខាលើផ្នែកដែលនៅសល់ (ផ្នែកទី 2) ។ ពិនិត្យមើលពាក្យសុំឡើងវិញ ដើម្បីឲ្យប្រាកដថាពាក្យនេះត្រូវបានបំពេញសព្វគ្រប់ ហើយផ្ញើមកវិញនៅក្នុងស្រោមសំបុត្រដែលបានផ្តល់ជូនទៅកាន់៖

Southern California Edison
Medical Baseline Department
P.O. Box 9527
Azusa, CA 91702

*កំណត់សម្គាល់សំខាន់៖ មុនពេលដែលអ្នកទទួលបានការអនុម័តសម្រាប់ការលៃទុក គោលទំហៀបវេជ្ជសាស្ត្រ អ្នកតំណាង SCE អាចចុះមកមើលផ្ទះរបស់អ្នកសម្រាប់គោលបំណងបញ្ជាក់ ផ្ទៀងផ្ទាត់បរិក្ខារ។*

## ចុះបើម្ចាស់អចលនទ្រព្យ ឬភាគីផ្សេងទៀតបង់ថ្លៃអគ្គីសនីឲ្យខ្ញុំ?

ប្រសិនបើម្ចាស់អចលនទ្រព្យ ឬភាគីមួយផ្សេងទៀតបង់អត្រាតម្លៃសម្រាប់គ្រួសារច្រើនក្នុងស្រុក (DM) សម្រាប់អគ្គិសនីនៅក្នុងលំនៅដ្ឋានរបស់អ្នក គាត់ក៏ត្រូវតែចុះហត្ថលេខាលើពាក្យស្នើសុំប្រាក់ឧបត្ថម្ភគោលទំហៀបសំរាប់ផ្នែកវេជ្ជសាស្ត្ររបស់អ្នកជាមួយអ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្ររបស់អ្នកផងដែរ។

## តើការលៃទុកនេះនឹងលេចនៅលើវិក្កយបត្ររបស់ខ្ញុំនៅពេលណា?

ប្រសិនបើបានអនុម័ត ការលៃទុកគោលទំហៀបវេជ្ជសាស្ត្ររបស់អ្នកនឹងបង្ហាញនៅលើវិក្កយបត្រជាបន្តបន្ទាប់ទាំងអស់របស់អ្នកក្នុងខណៈត្រូវបានចុះឈ្មោះនៅក្នុងកម្មវិធីនេះ។

## តើខ្ញុំនឹងត្រូវធ្វើ ពាក្យសុំរបស់ខ្ញុំជាថ្មីឡើងវិញដែរឬទេ?

ពាក្យស្នើសុំការលៃទុកគោលទំហៀប វេជ្ជសាស្ត្រទាំងអស់ត្រូវតែធ្វើថ្មីឡើងវិញទៅតាមរយៈកាល។ យើងនឹងផ្ញើទម្រង់បែបបទមួយដើម្បីឱ្យអ្នកធ្វើដូច្នេះមុនកាលបរិច្ឆេទធ្វើថ្មីឡើងវិញដែលបានកំណត់ពេលរបស់អ្នក។ ភាពញឹកញាប់នៃការធ្វើថ្មីឡើងវិញគឺផ្អែកលើប្រភេទនៃជំងឺ និងបរិក្ខារពេទ្យដែលប្រើប្រាស់។ ជាផ្នែកមួយនៃដំណើរការត្រួតពិនិត្យឡើងវិញនេះ អ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ របស់អ្នកអាចនឹងត្រូវបានស្នើសុំឲ្យបំពេញទម្រង់បែបបទធ្វើថ្មីឡើងវិញនិងផ្ទៀងផ្ទាត់ថាអ្នកនៅតែត្រូវការបរិក្ខារពេទ្យដដែល។

## ចុះបើខ្ញុំផ្លាស់ទីលំនៅ?

ប្រសិនបើអ្នកផ្លាស់ទីលំនៅនៅក្នុងទឹកដីសេវាកម្មរបស់ SCE ការលៃទុកគោលទំហៀបវេជ្ជសាស្ត្ររបស់អ្នកអាចត្រូវបានផ្ទេរទៅអាសយដ្ឋានសេវាកម្មថ្មីរបស់អ្នក។ ចំពោះព័ត៌មានបន្ថែម សូមទូរស័ព្ទមកលេខ **1-800-447-6620។**

## ចុះបើចរន្តអគ្គិសនីដាច់?

អតិថិជនទាំងអស់ដែលពឹងផ្អែកលើបរិក្ខារពេទ្យ ឬបរិក្ខារទ្រទ្រង់ជីវិតដែលដើរដោយថាមពលអគ្គិសនី ដើម្បីរស់រានមានជីវិតគួរតែត្រៀមគ្រប់ពេលវេលារៀបចំនូវប្រព័ន្ធ ថាមពលបម្រុង ឬផែនការផ្សេងទៀតដែលចាំបាច់ដើម្បីធានាសុខភាព និងសុខមាលភាពរបស់ពួកគេក្នុងអំឡុងពេលដាច់ចរន្តអគ្គិសនី។ SCE មិនផ្តល់ម៉ាស៊ីនភ្លើងបម្រុងទេ។

ក្រុមហ៊ុនផលិតតែងតែផ្តល់ប្រព័ន្ធថាមពល បម្រុងជាថ្ម (ឧបករណ៍ចល័ត) សម្រាប់បរិក្ខាររបស់ខ្លួន។ ប្រសិនបើអ្នកត្រូវការជំនួយក្នុងការកំណត់ថាតើឧបករណ៍របស់អ្នកមានប្រព័ន្ធ បម្រុងទុកជាថ្មដែរឬអត់នោះ សូមទាក់ទងក្រុមហ៊ុនផលិតឧបករណ៍នោះ។

*ចំណំា៖ យើងនឹងព្យាយាមជូនដំណឹងទៅអតិថិជននៃប្រាក់ឧបត្ថម្ភគោលទំហៀបសម្រាប់ថ្លៃពេទ្យតាមរយៈការហៅតាមទូរស័ព្ទដោយស្វ័យប្រវត្តិ ប្រសិនបើតំបន់លំនៅដ្ឋានរបស់ពួកគេត្រូវបានកំណត់ពេលឲ្យជួបប្រទះនឹងបញ្ហាដាច់ចរន្តអគ្គិសនីបង្វិលឆ្លាស់វេនគ្នា ឬប្រសិនបើ ការងារ ថែទាំនឹងត្រូវបានធ្វើឡើង។*

